# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1621

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការកាត់បន្ថយការបំពុល និងការរក្សាលំហូរបរិស្ថានក្នុងតំបន់សមុទ្រអាស៊ីខាងកើតតាមរយៈការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 30/05/23 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/05/27 |
| ៣. ចំណាយគម្រោងសរុប | $737,400 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងបរិស្ថាន |
| RESPONSIBLE UNIT | Department of Water Quality Management, General Directorate of Environmental Protection |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៥. ស្ថានភាពគម្រោង | គម្រោងកំពុងដំណើរការ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ដើម្បីកែលម្អការគ្រប់គ្រងធនធានទឹកតាមវិធានចម្រុះ កាត់បន្ថយបន្ទុកបំពុលពីសារជាតុចិញ្ចឹម និងសកម្មភាពបំពុលពីដីគោក រក្សានិរន្តរភាពលំហូរបរិស្ថានទឹក និងកាត់បន្ថយភាពងាយរងគ្រោះនៃអាកាសធាតុ តាមរយៈការបង្ហាញការធ្វើផែនការ និងការពង្រឹងការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

ការសម្របសម្រួលគោលនយោបាយគាំទ្រ (ការបណ្តុះបណ្តាលជំនាញនិងធនធានមនុស្ស ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងវិធានការផ្នែកហិរញ្ញប្បទាន)

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពត,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ដើម្បីបង្កើតយន្តការនៃមុខងារ IRBM នៅព្រែកកំពង់បាយដែល និងតំបន់ឆ្នេរជាប់ពាក់ព័ន្ធ ដើម្បីកាត់បន្ថយការបំពុល និរន្តរភាពលំហូរបរិស្ថានទឹក និងការការបន្សាំទៅនឹងភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

• វាយតម្លៃជាមូលដ្ឋានដើម្បីគ្រប់គ្រងការបំពុលសមុទ្រពីដីគោក៖
ធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងពីស្ថានភាពអភិបាលកិច្ច សេដ្ឋកិច្ចសង្គម និងអេកូឡូស៊ី ចន្លោះប្រហោង និងតម្រូវការជាអាទិភាពនៃអាងទន្លេ

• គម្រោង IRBM សាកល្បងសម្រាប់ធ្វើឱ្យប្រសើរឡើង នូវអភិបាលកិច្ច និងការគ្រប់គ្រងអាងទន្លេ/អនុអាងទន្លេ និងតំបន់ឆ្នេរដែលពាក់ព័ន្ធ៖
គម្រោង IRBM សាកល្បងបង្ហាញអំពីយន្តការអភិបាលកិច្ច និងឧបករណ៍សម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រភព នៃការគ្រប់គ្រងសមុទ្រនៅក្នុងអាងទន្លេ/ អនុអាងទន្លេ អាទិភាពចំនួន ៧ និងតំបន់ឆ្នេរ
យុទ្ធសាស្រ្តគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ និងផែនការសកម្មភាពក្នុងអាងអាងទន្លេ/ អនុអាងទន្លេ អាទិភាព ចំនួន ៧ ត្រូវបានបង្កើត អនុម័ត និងផ្តួចផ្តើមគំនិត។

• ការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព៖
ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងចំណេះដឹង/ការចែករំលែកចំណេះដឹងផ្នែក IRBM និងការធ្វើឱ្យសមត្ថភាពក្នុងចំណោម ប្រទេសដែលចូលរួម ដៃគូ និងបណ្តាញ

• ការតាមដាន និងការវាយតម្លៃដើម្បីសម្រេចបាននូវគោលបំណង:
ការត្រួតពិនិត្យ និងវាយតម្លៃកម្រិតគម្រោងក្នុងការអនុលោមតាម UNDP និងតម្រូវការ M&E ជាក់លាក់របស់ GEF។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ប្រជាជន និងសេដ្ឋកិច្ចនៃអាងទន្លេកំពង់បាយ ពឹងផ្អែកយ៉ាងខ្លាំងលើសេវាអេកូឡូស៊ី ដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងប្រព័ន្ធជារាសាស្ត្រអាងទន្លេ។ ជាការពិតណាស់ ប្រជាជនក្នុងតំបន់ពឹងផ្អែកលើធនធានទឹកនៃអាងទន្លេជាប្រភពទឹកសម្រាប់កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងការដឹកជញ្ជូន។ ជាឧទាហរណ៍ យោងតាមការសិក្សារបស់ JICA អាងទន្លេកំពង់បាយ គឺជាប្រភពតែមួយគត់សម្រាប់ទាញយកទឹកស្អាតសម្រាប់ប្រជាជនក្នុងក្រុងកំពតហើយបរិមាណទឹកដែលប្រមូលបានពីអាងគឺ ៥.៨៧៥ ម៣/ថ្ងៃ (JICA, 2010)។ ក្រៅពីនេះ អាងទន្លេកំពង់បាយក៏ជាប្រភពថាមពលដែលអាចបង្កើតថាមពលអគ្គិសនីបាន ១៩៤ មេហ្គាវ៉ាត់ តាមរយៈទំនប់វារីអគ្គិសនី (Sinohydro, 2017)។ យោងតាមស្ថិតិពី NCSNDD គ្រួសារចំនួន ៦៦១ ប្រើប្រាស់ប្រព័ន្ធជារាសាស្ត្រដែលមានទឹកពីអាងទន្លេសម្រាប់ការងារ កសិកម្មរបស់ពួកគេ។ ការថែរក្សាគុណភាពនិងបរិមាណធនធានទឹកក្នុងអាងទន្លេនៃកំពង់បាយកំពុងប្រឈមមុខនឹងបញ្ហាដោយសារតម្រូវការទឹកកើនឡើងដោយកំណើនប្រជាជន និងកំណើននៃសកម្មភាពឧស្សាហកម្ម និងកសិកម្ម។

ទោះបីជាអាងទន្លេកំពង់បាយផ្តល់អត្ថប្រយោជន៍ដល់សង្គម សេដ្ឋកិច្ច និងបរិស្ថានក៏ដោយ ក៏អាងទន្លេកំពុងប្រឈមនឹងការថយចុះគុណភាពទឹកនិងកង្វះអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានទឹក។ ការថយចុះគុណភាពទឹកនៃព្រែកកំពង់បាយ ពាក់ព័ន្ធនឹងការបង្ហូរទឹកកខ្វក់ ដែលមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មចូលទៅក្នុង អាងទន្លេ ការហូរជ្រាបចេញពីសកម្មភាពកសិកម្ម និងកាកសំណល់រឹង។ ការតភ្ជាប់ ទៅនឹងប្រព័ន្ធលូរួមមានត្រឹមតែ ៣.០៦% ហើយមានផ្ទះចំនួនតិចតួចណាស់ដែលមានអាងស៊ុបទិក (KP, 2013) ។ លើសពីនេះទឹកកខ្វក់ភាគច្រើនត្រូវបានបង្ហូរទៅកាន់ប្រព័ន្ធទឹកធម្មជាតិដោយមិនមានការសម្អាតបឋម។

អត្រាការប្រមូលសំណល់នៅព្រែកកំពង់បាយនៅមានកម្រិតនៅឡើយ ដោយកាកសំណល់ជាច្រើននៅតែដុត កប់ ឬបោះចោលនៅតាមទីសាធារណៈ និងចូលទៅក្នុងទឹក ។ ជាលទ្ធផល ការបំពុលបរិស្ថានក្នុងព្រែកកំពង់បាយដោយសារ កាកសំណល់រឹងកំពុងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ទេសចរណ៍ និងការបំពុលទឹក។ ទោះបីជាមិនមានស្ថិតិ បង្ហាញពីបរិមាណសំណល់រឹងនៅតំបន់អាងទន្លេក៏ដោយ ប៉ុន្តែបើតាមស្ថិតិដែលអាចរកបានទីក្រុងកំពតទាំងមូលមាន កាកសំណល់ប្រហែលពី ១៥ ទៅ ២០ តោន/ថ្ងៃ ដែលប្រមូលបាន ហើយយកទៅបោះចោលនៅកន្លែងចាក់សំរាមចំហ។ ជាការពិត បរិមាណពិតនៃការបង្កើតសំណល់រឹងនៅក្នុងខេត្តកំពត នឹងមានកាន់តែច្រើនដោយសារសេវាប្រមូលសំរាម គ្របដណ្តប់តែផ្លូវធំ ផ្សារធំ និងកណ្តាលក្រុងកំពត (CSARO, 2011)។

តំបន់ឆ្នេរព្រែកកំពង់បាយ មានស្មៅសមុទ្រ ២៥.២៥០ ហិកតា ផ្កាថ្ម ៩៥៣ ហិកតា និងព្រៃកោងកាង ១.៩៦០ ហិកតា។ ទាំងនេះគឺជាធាតុផ្សំដ៏សំខាន់នៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ ដែលទ្រទ្រង់ជីវៈចម្រុះ និងធនធានជលផលនៅក្នុងតំបន់ជុំវិញ។ សមុទ្រក្នុងខេត្តកំពតក៏កំពុងអភិរក្សប្រភេទសត្វកម្រដូចជា ជ្រូកសមុទ្រ ផ្សោតសមុទ្រ និងអណ្តើកសមុទ្រ (KP, 2013)។ ការប៉ាន់ប្រមាណតម្លៃសេដ្ឋកិច្ចសុទ្ធប្រចាំឆ្នាំនៃស្មៅសមុទ្រនៅកម្ពុជាគឺ ១.១៨៦ ដុល្លារអាមេរិក/ហិកតា/ឆ្នាំ ខណៈពេលដែលព្រៃកោងកាងមានចំនួន ៨៨២.៣៥ ដុល្លារអាមេរិក/ហិកតា/ឆ្នាំ (UNDP, 2007)។ ដូច្នេះហើយកង្វះវិធានការគ្រប់គ្រងការបំពុលទឹកនៅព្រែកកំពង់បាយ នឹងធ្វើឱ្យមានការបំពុលទឹកក្នុងសមុទ្រហើយជាលទ្ធផលនឹងនាំឱ្យបាត់បង់ធនធានសមុទ្រសំខាន់ៗសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច សង្គម និងធនធានធម្មជាតិក្នុងអាងទន្លេ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ផលប្រយោជន៍ដោយផ្ទាល់៖ ក្រសួងបរិស្ថាននឹងមានភាពប្រសើរឡើងនូវការអភិវឌ្ឍសមត្ថភាពក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងអាងទន្លេ ការគ្រប់គ្រងគុណភាពទឹក និងការធ្វើផែនការ។
ផលប្រយោជន៍ដោយប្រយោល៖ គម្រោងនឹងចូលរួមចំណែកដល់ស្ថាប័នផ្សេងៗដូចជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងអាជ្ញាធរខេត្តកំពត។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបរិស្ថានតាមរយៈការកែលម្អគុណភាពទឹកនិងបរិមាណនៃព្រែកកំពង់បាយ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ទាំងពីរ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៧. គុណភាពទឹក (ទូទៅ)** | 30 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**សំឡេងពីសហគមន៍ដែលរងផលប៉ះពាល់ ជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះនឹងត្រូវបានឮក្នុងអំឡុងពេលអនុវត្តគម្រោង។ គម្រោងនេះនឹងផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់សុខភាពប្រជាជននៅទីតាំងគម្រោង (គុណភាព និងបរិមាណទឹក) ហើយ ក្រុមក្រីក្រ និងងាយរងគ្រោះនឹងទទួលបានអត្ថប្រយោជន៍សុខភាពពីវិធានការត្រួតពិនិត្យការបំពុលដែលអនុវត្តដោយរដ្ឋាភិបាល។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

- **ក្រសួងបរិស្ថាន (ដែលមានអគ្គនាយកដ្ឋានគាំពារបរិស្ថាន) ចូលរួមផ្តល់នូវគោលនយោបាយ បច្ចេកទេសនិងការគាំទ្រផ្សេងទៀតដែលអាចត្រូវបានប្រមូលផ្តុំនៅក្នុងវិស័យជំនាញរបស់ខ្លួនរួមទាំងការប្រើប្រាស់ធនធានបន្ថែមតាមរយៈកម្មវិធី និងគម្រោងដែលមានស្រាប់ ដើម្បីគាំទ្រក្នុងចំណោមអ្នកដទៃទៀត ការបង្កើតយន្តការ IRBM ដែល មានមុខងារ។**
- **ភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់សមុទ្រអាស៊ីបូព៌ា (PEMSEA) ជួយ សម្របសម្រួលក្នុងការរៀបចំផែនការការងារ និងថវិកាសម្រាប់ប្រទេសកម្ពុជា ដោយផ្អែកលើក្របខ័ណ្ឌលទ្ធផល។**

២៣. [illegible] ដែល បណ្តាល ឲ្យ [illegible])

• បានរៀបចំសិក្ខាសាលាថ្នាក់ជាតិសម្រាប់គម្រោង GEF/UNDP/ASEAN ស្ដីពីការកាត់បន្ថយការបំពុល និងការរក្សាលំហូរបរិស្ថានសមុទ្រក្នុងតំបន់អាស៊ីខាងកើតតាមរយៈការអនុវត្តការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះក្នុងបណ្ដាប្រទេសអាស៊ាន បានធ្វើនៅប្រទេសកម្ពុជា ស្ថិតក្នុងខេត្តកំពត ចាប់ពីថ្ងៃទី ២៨-២៩ ខែមិថុនា ឆ្នាំ ២០២៣

• បានរៀបចំការកសាងសមត្ថភាពលើកទី១ អំពី IRBM និង ICM ចាប់ពីថ្ងៃទី១៤-១៧ ខែវិច្ឆិកា ឆ្នាំ ២០២៣ នៅខេត្តកំពត

• បានរៀបចំសេចក្ដីសម្រេច ស្ដីពី«ការបង្កើតក្រុមការងារអន្តរក្រសួងដឹកនាំ អនុវត្តគម្រោងកាត់បន្ថយការបំពុល និងការរក្សាលំហូរបរិស្ថានក្នុងតំបន់សមុទ្រអាស៊ីខាងកើតតាមរយៈការអនុវត្តការគ្រប់គ្រងអាងទន្លេតាមវិធានចម្រុះ» (ឆ្នាំ ២០២៤)

• បានចូលរួមរៀបចំរបាយការណ៍ថ្នាក់តំបន់ ស្ដីពី«ការវិភាគយេនឌ័រ និងបរិយាបន្នសង្គម» សម្រាប់ខេត្តកំពត (ខែឧសភា ឆ្នាំ២០២៤)

• បានចូលរួមរៀបចំកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោងរួមថ្នាក់តំបន់លើកទី២ (2nd RSC) កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤

• បានរៀបចំកិច្ចកិច្ចប្រជុំលើកទី១ ក្រុមការងារអន្តរក្រសួងដឹកនាំគម្រោង ថ្ងៃទីកាលពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ នៅខេត្តកំពត។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

8

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

GEF: GEF ផ្ដល់ជំនួយឥតសំណងតាមរយៈកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ដែលជាទីភ្នាក់ងារ អនុវត្តក្នុងកិច្ចសហប្រតិបត្តិការជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) កំពុងគាំទ្រគម្រោងថ្នាក់តំបន់។

UNDP
បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការគម្រោងជាមួយនឹងភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់តំបន់សមុទ្រអាស៊ីបូព៌ា (PEMSEA) Resource Facility (PRF) ដែលបានអនុញ្ញាតឱ្យ PRF ជាទីភ្នាក់ងារប្រតិបត្តិនៃគម្រោងនេះ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្ដែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចន្ត |
| **ចំណាយប្រតិបត្តិ** | 12.5 | 9.0 | 0.0 | 0.0 | 3.0 | 0.0 | 3.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 12.5 | 9.0 | 0.0 | 0.0 | 3.0 | 0.0 | 3.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 229.3 | 105.7 | 71.1 | 170.6 | 79.6 | 0.0 | 250.2 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 18.3 | 10.0 | 4.5 | 28.5 | 16.5 | 0.0 | 45.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្ដុះបណ្ដាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 211.0 | 95.7 | 66.6 | 142.1 | 63.1 | 0.0 | 205.2 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 241.8 | 114.7 | 71.1 | 170.6 | 82.6 | 0.0 | 253.2 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 241.8 | 114.7 | 71.1 | 170.6 | 82.6 | 0.0 | 253.2 | |
| | | | | | | | | |
| Global Environment Facility | 241.8 | 114.7 | 71.1 | 170.6 | 82.6 | 0.0 | 253.2 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 241.8 | 114.7 | 71.1 | 170.6 | 82.6 | 0.0 | 253.2 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: